អគ្គនាយកដ្ឋានកសិកម្ម

នាយកដ្ឋានផលិតកម្ម
និងបសុព្យាបាល

គម្រោងអភិវឌ្ឍន៍កសិកម្ម
និងជំរុញកំណើនសេដ្ឋកិច្ច

# បច្ចេកទេសចិញ្ចឹមមាន់ ជ្រូក និងគោ ជាលក្ខណៈគ្រួសារ



រៀបចំដោយ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល
សហការជាមួយ អគ្គនាយកដ្ឋានកសិកម្ម

ខែកក្កដា ឆ្នាំ២០១៣

## មាតិកា ទំព័រ


អារម្ភកថា......v

### ផ្នែកទី១ : បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ

លក្ខណៈល្អប្រសើរនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក......៣
គុណសម្បត្តិនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក......៤
ជំពូក ១ : ទ្រុងសម្រាប់ចិញ្ចឹមមាន់ ......៥
១. ទំហំទីកន្លែងរស់នៅ ......៥
២. ទ្រុងសម្រាប់ថែរក្សាកូនមាន់......៥
៣. ទ្រុងមាន់ធំ......៦
៤. ស្នូកចំណី និងស្នូកទឹក ......៧
ជំពូក ២ : ពូជ និងការបង្កាត់ពូជមាន់ ......៩
១. ការបង្កកំណើត ......៩
២. ការបង្កជាស៊ុត និងការក្រាប ......៩
៣. ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់ ......៩
៤. ការភ្ញាស់ស៊ុត និងការញាស់ ......៩
៥. ការជ្រើសកូនមាន់មកចិញ្ចឹម ......១១
៦. ការជ្រើសរើសបាមាន់ ......១១
៧. ការជ្រើសរើសមេមាន់......១២
៨. ការបង្កាត់ពូជមាន់ ......១២
ជំពូក ៣ : វដ្តផលិតកម្មមាន់ និងការថែរក្សាកូនមាន់ ......១៤
១. វដ្តផលិតកម្មមាន់ ......១៤
២. ការថែរក្សាកូនមាន់ទើបញាស់ ......១៤
ជំពូក ៤ : ការកែលំអពូជ និងការជម្រុះមាន់ ......១៧
១. ការបង្កាត់ពូជ ......១៧
២. ការជម្រុះ ......១៧
ជំពូក ៥ : ចំណីអាហារសម្រាប់មាន់ ......១៨
១. ការផ្តល់ចំណី ......១៨
២. វត្ថុធាតុដើមសម្រាប់ផ្សំចំណី ......១៨
៣. សមាសធាតុចំណីសំបូរជាតិសាច់ (ប្រូតេអ៊ីន) ......១៩
៤. សមាសធាតុចំណីសំបូរថាមពល ......២០
៥. សមាសធាតុចំណីសំបូរជីវជាតិរ៉ែ......២០
៦. សមាសធាតុចំណីសំបូរវីតាមីន ......២១

៧. ការចិញ្ចឹមជន្លេនក្រហម សម្រាប់ជាចំណីបំប៉ន ..............................................២១
៨. ការផលិតកូនដង្កូវ ..............................................២៣
ជំពូក ៦ : ការផ្តល់ចំណី និងទឹកដល់មាន់ ..............................................២៤
១. ការផ្តល់ចំណីដល់មេ បា និងមាន់ធំ ..............................................២៤
២. ការផ្តល់ចំណីដល់កូនមាន់ ..............................................២៤
៣. ការផ្តល់ទឹក ..............................................២៥
ជំពូក ៧ : ជីវសុវត្ថិភាព និងការធ្វើអនាម័យ..............................................២៦
១. អនាម័យកន្លែងចិញ្ចឹម ..............................................២៦
២. អនាម័យចំណីអាហារ និងទឹក..............................................២៦
៣. ការរៀបចំចិញ្ចឹមមាន់ ..............................................២៦
៤. អនាម័យលើការឆ្លងពីក្រៅ និងឧបករណ៍ចិញ្ចឹម ..............................................២៧
ជំពូក ៨ : ការការពារជម្ងឺមាន់ ..............................................២៨
១. ស្ថានភាពសុខភាព ..............................................២៨
២. លក្ខណៈរបស់មាន់ ..............................................២៨
៣. ជម្ងឺដែលច្រើនកើតមានលើមាន់ ..............................................៣០
៤. លក្ខណៈទូទៅរបស់វ៉ាក់សាំង ..............................................៤១

## ផ្នែកទី២ : បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

ជំពូក ១ : ពូជជ្រូក និងការជ្រើសរើសពូជ..............................................៤៥
១. ពូជ ..............................................៤៥
២. ការជ្រើសរើសពូជ ..............................................៤៦
ជំពូក ២ : ការសាងសង់ទ្រុង ..............................................៤៨
១. ទីតាំង និងទំហំ ..............................................៤៨
២. កម្រាល និងទីធ្លា ..............................................៤៨
៣. ដំបូល ..............................................៤៩
ជំពូក ៣ : ការផ្តល់ចំណី និងទឹក ..............................................៥០
១. ការផ្តល់ចំណី ..............................................៥០
២. សមាសធាតុសំខាន់ៗក្នុងចំណី ..............................................៥១
៣. ការផ្តល់ទឹក..............................................៥២
ជំពូក ៤ : ការបង្កាត់ពូជ ..............................................៥៤
១. ជ្រូកបាក្មេង និងជ្រូកមេក្រមុំ ..............................................៥៤
២. មេជ្រូកផ្តាច់ដោះ ..............................................៥៤
៣. វដ្តនៃការរកឈ្មោល ..............................................៥៤
ជំពូក ៥ : ការថែទាំមេជ្រូក និងកូន ..............................................៥៦

# លក្ខណៈល្អប្រសើរនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក

ពូជមាន់ក្នុងស្រុកដែលប្រទះឃើញញឹកញាប់ជាងគេ គឺមាន់គក មាន់សំពៅ មាន់ប្រជល់ មាន់កណ្តូង មាន់ថៃ មាន់សំឡី មាន់ក្រញាស់ មាន់ខ្មៅ មាន់ស្គួយ ។ល។



មាន់គក



មាន់សំពៅ



មាន់ប្រជល់



មាន់កណ្តូង



មាន់ថៃ



មាន់សំឡី



មាន់ក្រញាស់



មាន់ខ្មៅ



មាន់ស្គួយ

## គុណសម្បត្តិនៃការចិញ្ចឹមមាន់ពូជក្នុងស្រុកៈ

- ធន់ទៅនឹងអាកាសធាតុ និងការលំបាកគ្រប់បែបយ៉ាង
- មិនចាំបាច់ផ្តល់នូវចំណីផ្សំ (ក្រុមហ៊ុន) ទាំងស្រុង ដោយអាចផ្សំពីចំណីធម្មជាតិ ដែលអាចរកបាននៅក្នុងភូមិ និងមានតម្លៃថោកសមរម្យ
- ងាយស្រួលក្នុងការថែទាំ
- ផ្តល់ស៊ុត ក្រាបភ្ញាស់ និងបណ្តើរកូនដោយខ្លួនវា
- មិនសូវកើតជម្ងឺ និងទប់ទល់ជាមួយជម្ងឺកាចសាហាវបានមួយចំនួន
- សាច់មាន់ស្រុកមានរសជាតិឆ្ងាញ់ និងពេញនិយម
- តម្រូវការទីផ្សារខ្ពស់ (មាន់សាច់ និងស៊ុត) និងមានតំលៃល្អ





# ជំពូក ១
# ទ្រុងសម្រាប់ចិញ្ចឹមមាន់

ទ្រុងមានសារៈសំខាន់ណាស់ សម្រាប់ការពារមាន់ធំ និងកូនមាន់ ពីការយាយីបំផ្លាញផ្សេងៗ និងអាចទប់ទល់អាកាសធាតុប្រែប្រួល ជាពិសេសកូនមាន់តូចៗ ទ្រុងមាន់ដែលល្អត្រូវមានលក្ខណៈដូចខាងក្រោម ៖

- ទីធ្លាទូលាយ
- មានខ្យល់អាកាសស្រឡះល្អ និងស្ងួត
- ងាយស្រួលក្នុងការបោសសម្អាត និងអនាម័យ
- មានទ្រនំសម្រាប់មាន់ដេក
- មានសំបុកគ្រប់គ្រាន់សម្រាប់មេមាន់ពង និងក្រាបពង

ដើម្បីឱ្យការចិញ្ចឹមមាន់បានរីកចំរើន និងធានាសុវត្ថិភាពនោះ កសិករត្រូវអនុវត្តតាមបច្ចេកទេសសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

## ១. ទំហំទីកន្លែងរស់នៅ

សម្រាប់មេមាន់មួយក្បាល និងកូនមាន់ពី១៥ ទៅ ២០ក្បាល ត្រូវការទំហំផ្ទៃដី ១.៥ម × ១.៥ម ។ ដូច្នេះ បើចិញ្ចឹមមេមាន់ ២០ក្បាល កសិករត្រូវមានផ្ទៃដីប្រហែល ៦០-៨០ម² ហើយដើម្បីឱ្យកូនមាន់មានចំនួនច្រើន និងចិញ្ចឹមបំប៉នរហូតដល់ពេលលក់មានសុខភាពល្អ កសិករត្រូវមានដីប្រមាណ១០០-១២០ម²។

## ២. ទ្រុងសម្រាប់ថែរក្សាកូនមាន់

ដើម្បីឱ្យកូនមាន់អាយុពី ១ ទៅ ៣០ថ្ងៃលូតលាស់ល្អ ត្រូវ ៖

- ធ្វើទ្រុងផុតពីដីកំពស់កន្លះម៉ែត្រ
- បាតទ្រុង និងជញ្ជាំងអាចធ្វើពីបន្ទះឫស្សី ឬក៏សំណាញ់ដែក ឬនីឡុង។
- បាតទ្រុងត្រូវក្រាលអង្កាម ឬកំទេចអាចម៍រណា (ដើម្បីរក្សាកំដៅ) រហូតដល់កូនមាន់មានអាយុ ៣០ថ្ងៃ ទើបលែងដាក់ ។
- ជញ្ជាំងទ្រុង និងពីលើទ្រុងពទ្ធ័ដោយបាវ ឬក្រដាសដើម្បីរក្សាកំដៅ ពិសេសពេលយប់ និងអាកាសធាតុត្រជាក់។

**បញ្ជាក់:**

នៅពេលកូនមាន់អាយុបាន ៣០ថ្ងៃ ត្រូវបញ្ជូនទៅដាក់ក្នុងទ្រុងបំប៉ន រហូតដល់ពេលលក់ ។



*ទ្រុងកូនមាន់ជញ្ជាំងធ្វើពីបន្ទះរនាបឬស្សី*



*ទ្រុងកូនមាន់ជញ្ជាំងធ្វើពីសំណាញ់*



*ដើម្បីរក្សាកំដៅ ត្រូវបាំងជុំវិញទ្រុងកូនមាន់*